រាជបណ្ឌិត្យសភាកម្ពុជា
វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ

*អត្ថបទស្រាវជ្រាវស្តីពី*

# ផ្ទះប្រពៃណីរបស់ជនជាតិដើមភាគតិចព្នង



*ដោយ ម៉ិល វាសនា*

ខែកុម្ភៈ ២០២២

# ផ្ទះប្រពៃណីរបស់ជនជាតិដើមភាគតិចព្នង

*ដោយ ម៉ិល វាសនា*

## សេចក្តីផ្តើម

ប្រសិនបើយើងចូលទៅក្នុងភូមិពូតាំង ឃុំរមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី ដែលជាភូមិនៃជនជាតិដើមភាគតិចព្នង នោះយើងស្ទើរតែពុំអាចកត់សម្គាល់បានសោះឡើយថា ភូមិនេះជាភូមិរបស់ជនជាតិដើមភាគតិចព្នង។ សម្លៀកបំពាក់ ផ្ទះសំបែង និង វត្ថុប្រើប្រាស់ផ្សេងៗ គឺមានលក្ខណៈដូចខ្មែរទៅហើយ។ ទោះជាយ៉ាងណា យើងសង្កេតឃើញមានផ្ទះជាលក្ខណៈប្រពៃណីរបស់ជនជាតិដើមភាគតិចព្នងប្រមាណជិត ១០ផ្ទះនៅឡើយ នៅក្នុងភូមិនេះ។

អត្ថបទនេះនឹងលើកឡើងអំពីផ្ទះជញជូញនិងផ្ទះជញបៃ ដែលជាផ្ទះប្រពៃណីរបស់ជនជាតិដើមភាគតិចព្នង រួមទាំងវត្ថុសម្ភារៈប្រើប្រាស់ចាំបាច់មួយចំនួននៅក្នុងផ្ទះផង។ អត្ថបទនេះនឹងពិនិត្យតែទៅលើអ្វីដែលយើងបានឃើញ បានដឹងនៅក្នុងភូមិពូតាំងនេះប៉ុណ្ណោះ។

## វត្ថុធាតុដើមនិងគ្រឿងបង្គុំផ្ទះ

ជាប្រពៃណី ផ្ទះរបស់ជនជាតិដើមភាគតិចព្នងនៅភូមិពូតាំង ឃុំរមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី ជាប្រភេទផ្ទះតៀមជាប់ផ្ទាល់នឹងផ្ទៃផែនដី ដែលអ្នកខ្លះហៅថា ផ្ទះអណ្តើក ។ ផ្ទះតៀមរបស់ជនជាតិដើមភាគតិចព្នងនេះមានពីរប្រភេទគឺ ផ្ទះជញជូញ(ផ្ទះតូច មានសសរ៣[1]) និងផ្ទះជញបៃ(ផ្ទះធំ មានសសរ៦)[2]។ ប្រសិនបើយើងមើលទម្រង់ពីខាងក្រៅ ផ្ទះទាំងពីរប្រភេទនេះមានលក្ខណៈដូចគ្នា ខុសតែទំហំប៉ុណ្ណោះ។

ផ្ទះតៀមទាំងពីរប្រភេទនេះប្រើប្រាស់នូវវត្ថុជាតុដើមសម្រាប់សាងសង់ដូចគ្នា មានជាអាទិ៍ ឫស្សី ស្បូវ និង កូនដើមឈើ ជាដើម ដែលជាវត្ថុជាតុដើមនៅក្នុងធម្មជាតិនៅជុំវិញភូមិដ្ឋានរបស់គេ។ ឈើឬក្តារគឺពុំមែនជាវត្ថុជាតុដើមសម្រាប់សាងសង់ផ្ទះរបស់ជនជាតិដើមភាគតិចព្នងដូចជនជាតិខ្មែរ

---

[1] សំដៅដល់សសរកណ្តាលផ្ទះ។

[2] ម៉ាក់ ទៀង (ហៅ ក្ញិ ណឹប) ជនជាតិព្នង អាយុ៣៩ឆ្នាំ រស់នៅក្នុងភូមិពូតាំង ឃុំរមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី។ (សម្ភាសន៍ថ្ងៃទី ២ ខែមករា ឆ្នាំ២០២១)

រស់នៅទំនាបកណ្ដាលឡើយ ដែលកត្តានេះគឺមួយផ្នែកអាចដោយសារពួកគេខ្វះសម្ភារៈសម្រាប់អារកាត់និងអារច្រៀកដើមឈើធំៗ។

ឫស្សីត្រូវប្រើជាវត្ថុធាតុដើមសម្រាប់ធ្វើជញ្ជាំងផ្ទះ ធ្វើរានដេក ធ្វើបង្កង់ និងរានដាក់ចានឆ្នាំងជាដើម។ ស្បូវត្រូវប្រើជាវត្ថុធាតុដើមសម្រាប់ក្រងជាកណ្ដាបសម្រាប់ប្រក់ដំបូលផ្ទះ ឯកូនដើមឈើត្រូវប្រើជាវត្ថុធាតុដើមសម្រាប់ធ្វើជាសសរកណ្ដាលផ្ទះនិងសសរជុំវិញផ្ទះសម្រាប់ចងជញ្ជាំងភ្ជាប់។ ជាទូទៅ គ្រឿងបង្គុំផ្ទះទាំងឡាយពុំមានការឈូសរំលីងឬបិតឱ្យល្អស្អាតឡើយ ជាអាទិ៍ សសរផ្ទះ គឺគ្រាន់តែវាយយកសម្បកចេញប៉ុណ្ណោះ។

ជនជាតិដើមភាគតិចព្នងបែងចែកឫស្សីជាបីប្រភេទផ្សេងគ្នាគឺ ទើមឃ្វែរ(ឫស្សីឃ្វៃ) ទើមកាលរ(ឫស្សីពកស្ដើង) និង ទើមង៉ាល់រ(ឫស្សីពកក្រាស់)។ ប្រភេទឫស្សីពកមានប្រភេទក្រាស់ និងប្រភេទស្ដើង ហើយការយកមកប្រើប្រាស់ជាគ្រឿងបង្គុំផ្ទះទៀតសោត ក៏មានលក្ខណៈខុសគ្នាដែរ។ ប្រភេទឫស្សីទើមកាលរ ដែលជាប្រភេទឫស្សីស្ដើង ងាយពុះច្រៀក ងាយពត់ ត្រូវប្រើសម្រាប់ធ្វើជារនាបរានដេក។ ប្រភេទឫស្សីទើមឃ្វែរដែលជាប្រភេទឫស្សីក្រាស់ជាប់មាំ ត្រូវប្រើជាបង្កង់ដំបូលផ្ទះ។ ប្រភេទឫស្សីទើមឃ្វែរអាចប្រើជាបង្កង់បានរយៈពេលពី២ឆ្នាំ ទៅ ៣ឆ្នាំ តែបើប្រើប្រភេទឫស្សីផ្សេងគឺអាចប្រើបានត្រឹមរយៈពេលតែពីកន្លះឆ្នាំទៅ១ឆ្នាំប៉ុណ្ណោះ។[3]

ជាប្រពៃណី សម្រាប់ជនជាតិដើមភាគតិចព្នង ការសាងសង់ផ្ទះគឺជាការងាររបស់បុរស។ នារីអាចជួយលើការងារស្រាលៗ ដូចជា ក្រងស្បូវសម្រាប់ប្រក់ដំបូលផ្ទះ ជាដើម។ ពួកគេសាងសង់ផ្ទះដោយខ្លួនឯងក្នុងរង្វង់សមាជិកគ្រួសារ ឬ ដោយការជួយគ្នាក្នុងរង្វង់ញាតិជិតខាង។ នៅសម័យមុនប្រសិនបើគេប្រើជាងប្រមាណ៣នាក់ឬ៤នាក់ គេអាចសាងសង់ផ្ទះមួយដោយប្រើរយៈពេលប្រមាណ៣ខែ ក្នុងករណីគិតទាំងការរកវត្ថុធាតុដើមនិងគ្រឿងសម្រាប់សាងសង់ផ្ទះ ដែលប្រើកម្លាំងមនុស្សដឹកជញ្ជូនវត្ថុធាតុដើមទាំងនោះផង[4]។ ប៉ុន្ដែ បើក្នុងករណីមានវត្ថុធាតុដើមនិងគ្រឿងផ្ទះរួចស្រេច គេអាចប្រើរយៈពេលប្រមាណពីរសប្ដាហ៍សម្រាប់ការសងសង់ផ្ទះប្រពៃណីនេះ។

---

[3] ម៉ាក់ ទៀង (ហៅ ក្និ ណឹប) ជនជាតិព្នង អាយុ៣៩ឆ្នាំ រស់នៅក្នុងភូមិពូតាំង ឃុំរមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី។ (សម្ភាសន៍ថ្ងៃទី ២ ខែមករា ឆ្នាំ២០២១)

[4] នៅសម័យមុន ជនជាតិដើមភាគតិចមិនមានប្រើគ្រឿងយន្តឬកម្លាំងសត្វពាហនៈសម្រាប់ការដឹកជញ្ជូនឡើយ។



ផ្ទះប្រពៃណីរបស់ជនជាតិដើមភាគតិចព្នងនៅភូមិពូតាំង



ផ្ទះប្រពៃណីរបស់ជនជាតិដើមភាគតិចព្នងនៅភូមិពូតាំង

**រចនាសម្ព័ន្ធខាងក្នុងផ្ទះជញ្ជួញនិងផ្ទះជញ្ចៃ**

ដូចបានលើកឡើងខាងលើ ប្រសិនបើពិនិត្យលើទម្រង់ខាងក្រៅនៃផ្ទះតៀមរបស់ជនជាតិដើមភាគតិចព្នង វាងផ្ទះជញ្ជួញ(ផ្ទះតូច មានសសរ៣) និង ផ្ទះជញ្ចៃ(ផ្ទះធំ មានសសរ៦) គឺមានលក្ខណៈដូចគ្នា ខុសគ្នាតែទំហំប៉ុណ្ណោះ។ ប៉ុន្តែ បើពិនិត្យនៅផ្នែកខាងក្នុងផ្ទះគឺផ្ទះតៀមទាំងពីរប្រភេទនេះមានរចនាសម្ព័ន្ធដោយឡែកគ្នា។ គេធ្វើផ្ទះជញ្ជួញឬផ្ទះជញ្ចៃអាស្រ័យទៅតាមចំនួនសមាជិកគ្រួសាររបស់គេ។

នៅផ្នែកខាងក្នុងផ្ទះជញ្ជួញមានសសរកណ្តាលបណ្តោយផ្ទះមួយជួរចំនួន៣ដើម មានរានដេកស្មើរពេញមួយចំហៀងផ្ទះដោយប្រើសសរ៣ដើមនោះជាជើងទម្រនៅផ្នែកម្ខាង ហើយមួយចំហៀងផ្ទះទៀតជាទីលំហសម្រាប់ដើរនិងសម្រាប់ដាក់វត្ថុសម្ភារៈប្រើប្រាស់ចាំបាច់ផ្សេងៗនៅក្នុងផ្ទះ ដូចជា ជើងក្រាន រានដាក់ចានឆ្នាំង និង ពាងឬធុងទឹក ជាដើម ដែលអាចចាត់ទុកថាជាធាតុមួយនៃផ្ទះរបស់ជនជាតិដើមភាគតិចព្នងផងដែរ។ ជាទូទៅ គេដាក់ជើងក្រាននៅផ្នែកកណ្តាលនៃទីលំហ ហើយដាក់នៅខាងទីខ្ពស់ងាយជញ្ជាត់បាយឬចាក់ទឹកឱ្យហូរចេញក្រៅផ្ទះ មិនឱ្យសើមដោកជាំនៅខាងក្នុងផ្ទះ។

ក្រៅពីតួនាទីសម្រាប់ចម្អិនអាហារ ជើងក្រានក្នុងផ្ទះនោះក៏មានតួនាទីសម្រាប់ដុតកម្តៅក្នុងផ្ទះនៅរដូវរងារផងដែរ ដោយខេត្តមណ្ឌលគីរីជាតំបន់ខ្ពង់រាប សម្បូរដោយភ្នំនិងព្រៃឈើ ដែលមានអាកាសធាតុត្រជាក់ខ្លាំងនៅរដូវរងារ។ ជាមួយនេះ ជើងក្រានក៏នឹងជួយកម្តៅសម្ងួតស្រូវដែលមិនអាចហាលបាននៅរដូវភ្លៀងផងដែរ។

ដោយឡែក នៅផ្នែកខាងក្នុងផ្ទះជញ្ចៃ(ផ្ទះធំ មានសសរ៦) មានសសរកណ្តាលបណ្តោយផ្ទះចំនួនពីរជួរ(មួយជួរមានសសរចំនួន៣ដើម) និងមានរានដេកចំនួនពីរដែលរានដេកនីមួយៗប្រើសសរមួយជួរៗ(ចំនួន៣ដើម)ជាជើងទម្រនៅផ្នែកម្ខាង។ ដូច្នេះ ផ្ទះជញ្ចៃមានទីលំហសម្រាប់ដើរនៅផ្នែកកណ្តាលរវាងជួរសសរទាំងពីរជួរ និងមានរានដេកនៅអមទាំងពីរខាង។ នៅទីលំហកណ្តាលផ្ទះនោះ គេដាក់ជើងក្រានដែលអាចចាត់ទុកថាជាធាតុសំខាន់មួយនៃផ្ទះជនជាតិដើមភាគតិចព្នង។ នៅផ្នែកខាងក្នុងផ្ទះជញ្ចៃ គេមានធ្វើជាធ្នើនៅខាងលើសម្រាប់រក្សាស្រូវ(ជង្រុក?)។

ទាំងផ្ទះជញ្ជួញ(ផ្ទះតូច មានសសរ៣) ទាំងផ្ទះជញ្ចៃ(ផ្ទះធំ មានសសរ៦) គឺមិនមានខណ្ឌជាបន្ទប់នៅផ្នែកខាងក្នុងផ្ទះឡើយ។ ប៉ុន្តែ គេនឹងមានការបិទបាំងមួយផ្នែកក្នុងករណីមានស្ត្រីមានផ្ទៃ

ពោះធ្ងន់ទន្ទេ។ ជាទូទៅ ផ្ទះប្រភេទនេះត្រូវមានការជួសជុលកែលម្អម្តងក្នុងរយៈពេលពីរឬបីឆ្នាំ ជាពិសេសនៅផ្នែកដំបូលស្បូវដែលងាយពុកផុយ។ ផ្ទះប្រភេទនេះទៀតសោតក៏ពុំសូវមាំទាំអាចធន់ទ្រាំបាននឹងខ្យល់កន្ត្រាក់ឡើយ ដែលនាំឱ្យការជួសជុលឡើងវិញត្រូវធ្វើឡើងជាហូរហែ។



ផ្នែកខាងក្នុងនៃផ្ទះជញជួញ (សសរ៣ និងរានដេក)



ជើងក្រាន រានដាក់ចានឆ្នាំង ធុងទឹក និងចង្អេរពីលើជើងក្រានសម្រាប់កម្តៅសម្ងួតស្រូវ នៅក្នុងផ្ទះជញជួញ

## សម្ភារៈប្រើប្រាស់ក្នុងផ្ទះ

*ក្រៅពីជើងក្រាន ពានដាក់ចានឆ្នាំង និង ពាងឬធុងទឹក ដែលជាធាតុចម្បងៗនៅក្នុងផ្ទះជនជាតិដើមភាគតិចព្នង គឺមានសម្ភារៈប្រើប្រាស់ផ្សេងៗទៀតត្រូវរក្សាទុកនៅក្នុងផ្ទះនោះដែរ មានជាអាទិ៍ ពាងស្រា កាផា យ៉ុល(ឧបករណ៍ដាក់ត្រី) ចង្អេរ និង សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃផ្សេងៗទៀត។*

*ពាងស្រាជាវត្ថុដ៏មានសារៈសំខាន់មួយសម្រាប់វប្បធម៌ប្រពៃណីរបស់ជនជាតិដើមភាគតិចព្នង សម្រាប់ដាក់រក្សាស្រានៅពេលមានពិធីប្រពៃណីផ្សេងៗ ដូចជា ពិធីសែនស្រូវ ជាដើម។ ជនជាតិដើមភាគតិចព្នងមានទំនៀមដាំស្រូវចម្ការ មិនដាំស្រូវក្នុងស្រែដូចប្រជាជនខ្មែររស់នៅទំនាបកណ្តាលឡើយ។ ជាប្រពៃណី ជនជាតិដើមភាគតិចព្នងធ្វើពិធីសែនស្រូវចំនួនបីដងក្នុងមួយឆ្នាំ(មួយរដូវដាំស្រូវ) ក្នុងគោលបំណងឱ្យការធ្វើដំណាំស្រូវចម្ការរបស់ពួកគេប្រព្រឹត្តទៅដោយល្អប្រសើរនិងទទួលបានទិន្នផលល្អ។*

*ពិធីសែនស្រូវលើកទី១ គឺសែននៅពេលចាប់ផ្តើមធ្វើការដាំដុះស្រូវ មានដូចជា ការបែងចែកស្រូវសម្រាប់ដាំ និងការត្រួសត្រាយដុតព្រៃសម្រាប់ដាំស្រូវ ដើម្បីឱ្យព្រលឹងអ្នកថែរក្សាព្រៃបានស្ងប់សុខ មិនប្រកាន់ ហើយអនុញ្ញាតឱ្យប្រើប្រាស់ដីនោះធ្វើដំណាំចម្ការ ព្រមទាំងដើម្បីឱ្យដំណើរនៃការកាប់ឆ្ការព្រៃនោះប្រព្រឹត្តដោយជោគជ័យ សុខសប្បាយ គ្មានគ្រោះថ្នាក់។ លើកទី២ គេសែនស្រូវនៅពេលគេបូតស្រូវ ដើម្បីអំពាវនាវដល់ព្រលឹងស្រូវសណ្ឋិតក្នុងចម្ការបានផលស្រូវច្រើននៅពេលបូត ហើយគេយកចំបើងមកចងដាក់ជាប់នឹងសសរផ្ទះ។ លើកទី៣ គេធ្វើពិធីសែនស្រូវនៅពេលប្រមូលផលស្រូវ ដោយគេចាប់ផ្តើមជញ្ជូនយកស្រូវទៅរក្សានៅផ្ទះ។ គេធ្វើពិធីនេះដោយសមាជិកគ្រួសារទាំងអស់មកជួបជុំគ្នានៅចម្ការ ហើយរៀបចំពិធីសែនដោយដាក់សំណែនជាស្រា និងឈាមមាន់*[5] ។

*គ្រាប់អង្ករពីស្រូវចម្ការរបស់ជនជាតិដើមភាគតិចព្នងមានទំហំធំជាងគ្រាប់អង្ករពីស្រូវស្រែរបស់ប្រជាជនខ្មែរ និងមានទម្រង់ជាកំណាត់ខ្លីៗដែលអាចបណ្តាលមកពីការបុកយកអង្ករ។ ជនជាតិដើមភាគតិចព្នងយល់ថា អង្ករស្រូវដំណាំរបស់ខ្លួនមានរសជាតិឆ្ងាញ់ពិសារខុសប្លែកពីអង្ករដាក់លក់នៅទីផ្សារដែលពួកគេធ្លាប់បានទិញមកទទួលទាននៅពេលអង្កររបស់គេផ្គត់ផ្គង់មិនគ្រប់គ្រាន់។*

*ក្រៅពីពិធីសែនស្រូវបីដងក្នុងមួយឆ្នាំ ជនជាតិដើមភាគតិចព្នងនៅមានពិធីប្រពៃណីផ្សេងៗទៀត ដែលរៀងរាល់ពេលធ្វើពិធីគឺត្រូវតែមានស្រាជាគ្រឿងតង្វាយ។ ហេតុនេះ នៅក្នុងផ្ទះរបស់ជន*

---

[5] ហ៊ាន សុខុម ៖ *ក្រុមជនជាតិភាគតិចនៅកម្ពុជា* ភ្នំពេញ បោះពុម្ពឆ្នាំ២០១៩ ទំព័រ៤៦៦។

ជាតិដើមភាគតិចព្នងគឺតែងតែមានពាងស្រាប្រចាំសម្រាប់គ្រួសារនីមួយៗ។ ជាមួយគ្នានេះ ពួកគេតែងចេះបិតស្រាដោយខ្លួនឯង។

ពាងទឹកឬធុងទឹកគឺត្រូវប្រើសម្រាប់ដាក់រក្សាទឹកសម្រាប់បំពេញតម្រូវការផ្សេងៗនៅក្នុងផ្ទះ ដូចជា សម្រាប់ដាំស្ល និងសម្រាប់ទទួលទាន ជាដើម។ នៅសម័យមុន គេប្រើឃ្លោកសម្រាប់ដាក់ទឹករក្សាក្នុងផ្ទះ។

កាផាជាវត្ថុស្ពាយក្រោយខ្នងសម្រាប់ដាក់គ្រឿងវត្ថុផ្សេងៗ ដូចជា ស្រូវ បន្លែ ផ្លែឈើ និងអ្វីៗផ្សេងទៀត។ ដោយឡែក យ៉ុលជាវត្ថុចងចង្កេះ ប្រើសម្រាប់ដាក់ត្រីបន្ទាប់ពីចាប់ត្រីបាន។ យ៉ុលអាចធ្វើតូចឬធំទៅតាមចំណូលចិត្តរបស់អ្នកប្រើ។ យ៉ុលក្នុងរូបខាងក្រោមជាយ៉ុលដែលធ្វើសម្រាប់ប្រើក្នុងការសម្ដែងសិល្បៈ ជាពិសេសប្រើក្នុងរបាំជញ្ជាត់ត្រីរបស់ជនជាតិដើមភាគតិចព្នង។



ពាងស្រានៅក្នុងផ្ទះប្រពៃណីនៃជនជាតិដើមភាគតិចព្នង



កាផារបស់ជនជាតិដើមភាគតិចព្នង



យ៉ុលសម្រាប់ដាក់ត្រីរបស់ជនជាតិដើមភាគតិចព្នង



គ្រាប់អង្ករស្រែរបស់ខ្មែរ និង គ្រាប់អង្ករស្រូវដាំរបស់ជនជាតិដើមភាគតិចព្នង

## សេចក្តីសន្និដ្ឋាន

ប្រភេទផ្ទះជញជូញ(ផ្ទះតូច មានសសរ៣) និងផ្ទះជញចៃ(ផ្ទះធំ មានសសរ៦) របស់ជនជាតិដើមភាគតិចព្នងនៅភូមិពូតាំង ឃុំរមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី នៅសល់ប្រមាណតែជិត ១០ផ្ទះប៉ុណ្ណោះ ដោយភាគច្រើនគេបានសាងសង់ផ្ទះតាមលំនាំប្រជាជនខ្មែរដែលប្រើឈើជាមូលដ្ឋាន ជាពិសេសចាប់តាំងពីឆ្នាំ២០០៥ ដែលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ត្រូវកសាងនិងជួសជុលកែលម្អចូលទៅកាន់ខេត្តនេះ។

ការឆ្លងវប្បធម៌និងការវិវត្តនៃវប្បធម៌គឺជាកត្តាបពនុម័ត ដែលគេពុំអាចហាមឃាត់ឬទប់ស្កាត់បានឡើយ។ គុណភាពមិនសូវមាំទាំរបស់ផ្ទះ ការរើជួសជុលផ្ទះជាហូរហែ(យ៉ាងយូរពីរឬបីឆ្នាំម្តង) វត្តមានសម្ភារៈឧបករណ៍សម្រាប់ដឹកជញ្ជូន អារច្រៀក និងឈូសរំលីង ព្រមទាំងគ្រឿងបង្គុំផ្ទះផ្សេងៗនៅលើទីផ្សារប្រកបដោយគុណភាពនិងភាពងាយស្រួលសាងសង់ ជាមួយនឹងការវិវឌ្ឍនៃសង្គមជាតិនឹងធ្វើឱ្យបាត់បង់ផ្ទះជាអត្តសញ្ញាណរបស់ជនជាតិដើមភាគតិចព្នងនៅភូមិពូតាំងទាំងស្រុងនៅពេលខាងមុខ។ គេអាចរក្សាប្រភេទផ្ទះជញជូញនិងផ្ទះជញចៃបានតាមរយៈគោលនយោបាយលើកទឹកដល់ពួកគាត់ ហើយអាចឱ្យពួកគាត់រកចំណូលបានពីផ្ទះប្រភេទនេះ។

**ឯកសារពិគ្រោះ**

- ហ៊ាន សុខុម ៖ *ក្រុមជនជាតិភាគតិចនៅកម្ពុជា* ភ្នំពេញ បោះពុម្ពឆ្នាំ២០១៥ ។
- ម៉ាក់ ទៀង (ហៅ ក្ទិ ណឹប) ជនជាតិព្នង អាយុ៣៩ឆ្នាំ រស់នៅក្នុងភូមិពូតាំង ឃុំរមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ (សម្ភាសថ្ងៃទី ២ ខែមករា ឆ្នាំ២០២១)



ស្មេរនិងស្ត្រីជនជាតិព្នង នៅភូមិពូតាំង



ស្មេរនិងផ្ទះប្រពៃណីរបស់ជនជាតិដើមភាគតិចព្នង នៅភូមិពូតាំង